ទីដេអូ
អប់រំ
សុខភាព

# មុខវិជ្ជាអប់រំសុខភាព
## ថ្នាក់ទី៩

សមាសភាគទី៣ ៖ សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ

ជំពូកទី២ ៖ សុខភាពផ្លូវភេទ

មេរៀនទី១ ៖ គុណតម្លៃទាក់ទងនឹងរឿងផ្លូវភេទ

បង្រៀនដោយ ៖ អ្នកគ្រូ ឡុង គឹមណា

RHAC

# រំឭកមេរៀន

សប្តាហ៍មុននៅម៉ោងអប់រំសុខភាព

តើប្អូនបានរៀនមេរៀនអ្វី ?

មេរៀន ការរើសអើងអ្នករស់នៅជាមួយមេរោគអេដស៍

# រំឭកមេរៀន

តើប្រយោគខាងក្រោមមួយណាដែលបង្ហាញពីឥរិយាបថទប់ស្កាត់ការរើសអើងអ្នករស់នៅជាមួយមេរោគអេដស៍ ?

១- ប្រើពាក្យសម្តីមាក់ងាយ

២- មិនអនុញ្ញាតឱ្យរួមដំណើរជាមួយ

៣-ចែករំលែកអារម្មណ៍ខ្វល់ខ្វាយ ជួយថែរក្សា លើកទឹកចិត្ត ផ្តល់ចំណេះដឹងទាក់ទងច្បាប់ផ្សេងៗនិងស្វែងរកជំនួយ

៤- មិនទៅជិតឬទាក់ទងជាមួយ។

ចម្លើយដែលត្រឹមត្រូវទី៣

ការគាំទ្រពីសង្គមដើម្បីឱ្យយុវវ័យមានការអភិវឌ្ឍចំណេះដឹង ជំនាញ និងប្រកាន់ខ្ជាប់នូវគុណតម្លៃ សីលធម៌ និងឥរិយាបថ គឺជាគ្រឹះដ៏រឹងមាំក្នុងការជំរុញឱ្យមានជម្រើស ការគោរពអំពីសិទ្ធិ ទំនាក់ទំនងផ្លូវភេទ និងការបន្តពូជប្រកបដោយសុខុមាលភាព។

ថ្ងៃនេះប្អូនៗនឹងបានសិក្សានូវមេរៀនថ្មី ក្នុងសមាសភាពទី៣

សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ

ជំពូកទី២ សុខភាពផ្លូវភេទ

មេរៀនទី១ គុណតម្លៃទាក់ទងនឹងរឿងផ្លូវភេទ

# មេរៀនទី១ : គុណតម្លៃទាក់ទងនឹងរឿងផ្លូវភេទ

## គោលបំណង៖

- ប្រាប់និយមន័យ "គុណតម្លៃទាក់ទងនឹងរឿងផ្លូវភេទ"
- រៀបរាប់ពីប្រភេទនៃគុណតម្លៃទាក់ទងនឹងរឿងផ្លូវភេទ
- បកស្រាយពីប្រភេទនៃគុណតម្លៃទាក់ទងនឹងរឿងផ្លូវភេទ
- បណ្តុះស្មារតីឱ្យមានការគោរពសិទ្ធិគ្នាទៅវិញទៅមក ដើម្បីបញ្ជាក់ពីតម្លៃសម្រាប់មនុស្សគ្រប់រូបទាំងរឿងផ្ទាល់ខ្លួននិងអាជីពការងារនៅក្នុងសង្គម។

# ១- និយមន័យ

គុណតម្លៃ

ជាអារម្មណ៍ ឬជំនឿ ឬទស្សនវិស័យរបស់បុគ្គលដែលទាក់ទងនឹងបញ្ហាសំខាន់ៗក្នុងជីវិត។ វាជាធាតុដែលមនុស្សម្នាក់ៗត្រូវមានទាំងនៅក្នុងបរិបទគ្រួសារនិងសង្គម។

គុណតម្លៃគឺជាការផ្សារភ្ជាប់ទៅនឹងសកម្មភាពនិងឥរិយាបថរបស់បុគ្គលម្នាក់ៗដែលបានប្រព្រឹត្ត។

# ១- និយមន័យ (ត)

គុណតម្លៃទាក់ទងនឹងរឿងផ្លូវភេទ
គឺជាភាពថ្លៃថ្នូរ មានក្រមសីលធម៌ ចេះស្រឡាញ់រាប់អានគ្នា ចេះយល់អធ្យាស្រ័យគ្នា គោរពគ្នាទៅវិញទៅមក គោរពសិទ្ធិផ្លូវភេទ ដែលនាំមកនូវការរស់នៅជាមួយគ្នាប្រកបដោយសុខដុមរមនានៅក្នុងគ្រួសារនិងសហគមន៍។

តើគុណតម្លៃទាក់ទងនឹងផ្លូវភេទមានផ្សារភ្ជាប់ទៅនឹងអ្វីបន្ថែមទៀតឬទេ ?

# ១- និយមន័យ (ត)

- គុណតម្លៃទាក់ទងនឹងរឿងផ្លូវភេទ ផ្សារភ្ជាប់ទៅនឹងក្រមសីលធម៌ និងគោលការណ៍ក្រមសីលធម៌រឿងផ្លូវភេទ។
- ក្រមសីលធម៌រឿងផ្លូវភេទ គឺជាបទដ្ឋានសង្គមដែលបុគ្គលម្នាក់ៗត្រូវប្រកាន់យកការប្រព្រឹត្តរបស់ខ្លួនយើងម្នាក់ៗ ដោយផ្អែកលើគោលការណ៍ត្រូវ ឬខុស។
- គោលការណ៍ក្រមសីលធម៌ ដើរតួនាទីជាអ្នកនាំផ្លូវ ត្រួតពិនិត្យ រក្សាគុណភាព ជួយអ្នកក្នុងការត្រិះរិះពិចារណា និងការសម្រេចចិត្ត ដែលនឹងនាំទៅរកលទ្ធផលវិជ្ជមានរឿងផ្លូវភេទ ហើយមិនប៉ះពាល់ដល់បុគ្គលណាម្នាក់ ឬក្រុមណាមួយឡើយ។

# ១- និយមន័យ (ត)

- គុណតម្លៃ មានឥទ្ធិពលលើការសម្រេចចិត្តរបស់បុគ្គលម្នាក់ៗអំពីទំនាក់ទំនងផ្លូវភេទ មិត្តភក្តិ ទ្រព្យសម្បត្តិ និងការងារជាដើម។
- ទំនាក់ទំនងកាន់តែរឹងមាំ ប្រសិនបើបុគ្គលទាំងពីរនោះមាននិន្នាការនៃគុណតម្លៃប្រហាក់ប្រហែលគ្នា។

ទំនាក់ទំនងផ្លូវភេទជាផ្នែកមួយនៃសិទ្ធិមនុស្ស។

# ២- ប្រភេទនៃគុណតម្លៃ

តើប្អូនអាចប្រាប់បានឬទេថាប្រភេទនៃគុណតម្លៃមានអ្វីខ្លះ?

ប្រភេទនៃគុណតម្លៃជាអាទិភាពមាន៤៖

- ជម្រើស
- ភាពចម្រុះផ្សេងគ្នា
- ភាពស្មើគ្នា
- ការគោរព។

# ២- ប្រភេទនៃគុណតម្លៃ (ត)

អ្នកគ្រូសូមបែងចែកប្អូនជា៤ក្រុម ដើម្បីពិភាក្សាសំណួរ ។

# ២- ប្រភេទនៃគុណតម្លៃ (ត)

សំណួរ៖

១- តើជម្រើសនៃគុណតម្លៃទាក់ទងនឹងរឿងផ្លូវភេទមានអ្វីខ្លះ?ចូររៀបរាប់។

២- តើភាពចម្រុះផ្សេងគ្នានៃគុណតម្លៃទាក់ទងនឹងរឿងផ្លូវភេទមានអ្វីខ្លះ?
ចូររៀបរាប់

៣- តើភាពស្មើគ្នានៃគុណតម្លៃទាក់ទងនឹងរឿងផ្លូវភេទមានអ្វីខ្លះ?ចូររៀបរាប់។

៤- តើការគោរពនៃគុណតម្លៃទាក់ទងនឹងរឿងផ្លូវភេទមានអ្វីខ្លះ?ចូររៀបរាប់។

# ២- ប្រភេទនៃគុណតម្លៃ (ត)

សូមប្អូនៗយកសំណួរទាំងអស់ទៅពិភាក្សាតាមក្រុមសម្រាប់ឡើងបកស្រាយនៅសប្ដាហ៍ក្រោយក្នុងម៉ោងអប់រំសុខភាពរបស់អ្នកគ្រូ។ ឥឡូវនេះសូមប្អូនយកប៊ិចនិងបើកសៀវភៅសរសេរកត់មេរៀនសង្ខេបទុកសម្រាប់រៀននៅពេលក្រោយឬខ្វះចន្លោះដែលប្អូនចងចាំមិនទាន់បាន ។ អ្នកគ្រូនឹងហៅឃើតៗដើម្បីឱ្យប្អូនកត់ត្រា។

# មេរៀនសង្ខេប

- គុណតម្លៃ : គឺជាអារម្មណ៍ ឬជំនឿ ឬទស្សនវិស័យរបស់បុគ្គលដែលទាក់ទងនឹងបញ្ហាសំខាន់ៗក្នុងជីវិត។
- គុណតម្លៃទាក់ទងនឹងរឿងផ្លូវភេទ : គឺជាភាពថ្លៃថ្នូរ មានក្រមសីលធម៌ ចេះស្រឡាញ់រាប់អានគ្នា ចេះយល់អធ្យាស្រ័យគ្នា គោរពគ្នាទៅវិញទៅមក គោរពសិទ្ធិផ្លូវភេទ ដែលនាំមកនូវការរស់នៅជាមួយគ្នាប្រកបដោយសុខដុមនៅក្នុងគ្រួសារនិងសហគមន៍។

# ទន្លាយតម្លៃ

តើប្រយោគខាងក្រោមមួយណាបង្ហាញពីគុណតម្លៃមានឥទ្ធិពលលើការសម្រេចចិត្តរបស់បុគ្គល?

១- ពួកយើងបានឯកភាពគ្នាថាមានទំនាក់ទំនងជាមិត្តនឹងគ្នាសិនចុះ ចាំរៀនចប់មានការងារធ្វើសិនចាំពិភាក្សាគ្នាម្តងទៀតរឿងទំនាក់ទំនងស្នេហា

២- យើងមិនអាចរាប់អានគ្នាបានទេប្រសិនបើអ្នកនៅតែមិនឱ្យតម្លៃដល់ខ្ញុំ

៣- ជាមេគ្រួសារត្រូវមានសិទ្ធិចាត់ចែងទ្រព្យសម្បត្តិដោយមិនចាំបាច់ត្រូវពិភាក្សាជាមួយសមាជិកណាម្នាក់ក្នុងគ្រួសារឡើយ។

# ទេវាយតម្លៃ

ចម្លើយត្រឹមត្រូវទី១

១- ពួកយើងបានឯកភាពគ្នាថាមានទំនាក់ទំនងជាមិត្តនឹងគ្នាសិនចុះ ចាំរៀនចប់មានការងារធ្វើសិនចាំពិភាក្សាគ្នាម្តងទៀតរឿងទំនាក់ទំនងស្នេហា។

# ទោយតម្លៃ

តើអ្នកមានឥរិយាបថបែបណាដើម្បីបង្ហាញពីគុណតម្លៃដល់ដៃគូក្នុងរឿងផ្លូវភេទ ?

១- គំរាមផ្ដាច់ទំនាក់ទំនងជាមួយបើមិនធ្វើតាមបំណងរបស់អ្នក

២- ដាក់សម្ពាធឱ្យដៃគូធ្វើនូវអ្វីដែលគាត់មិនចង់ធ្វើ

៣- បោកបញ្ឆោតដៃគូ

៤- គោរពតាមការសម្រេចចិត្តរបស់ដៃគូដោយភាពថ្លៃថ្នូរ ការគោរពសិទ្ធផ្លូវភេទ។

ចម្លើយត្រឹមត្រូវទី៤

# លំហាត់

## កិច្ចការផ្ទះ

ចូរប្អូនៗធ្វើបន្តកិច្ចការក្រុមដែលបានបែងចែករួច ក្នុងមេរៀនគុណតម្លៃទាក់ទងនឹងរឿងផ្លូវភេទនេះ សម្រាប់ឡើងបង្ហាញនៅម៉ោងអប់រំសុខភាពសប្ដាហ៍ក្រោយ។

## បណ្ដាំផ្ញើ

ចូរប្អូនៗទាំងអស់គ្នា ចូលរួមគោរពគ្នាទៅវិញទៅមកដើម្បីបញ្ជាក់ពីតម្លៃសម្រាប់មនុស្សគ្រប់រូបទាំងរឿងផ្ទាល់ខ្លួននិងអាជីពការងារនៅក្រុងសង្គម។

សូមអរគុណ!